ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីជាសះស្បើយ ០២នាក់ និងមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ០២នាក់
# នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

## ១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **២១៧នាក់** (ស្មើនឹង ៨៧,៥០% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៤៦នាក់ និងបុរស ១៧១នាក់
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២៤៨នាក់** (ស្ត្រី ៥៩នាក់ និងបុរស ១៨៩នាក់។
- អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ និងឯកជន មានចំនួនសរុប **៣១នាក់៖**
    - នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត(ស្ត្រីជនជាតិកាណាដា ដែលមានវិជ្ជមានវីរុសកូវីដ-១៩ ខាងក្រោមនេះ)
    - នៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញមានចំនួន ២៦នាក់ (ជាបុរស)
    - នៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺមានចំនួន ០២នាក់ ជាបុរស
    - នៅមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល ចំនួន ០១នាក់ (ជាស្ត្រី)
    - ស្ត្រីជនជាតិកាហ្សាក់ស្តង់ (០១នាក់) ដែលបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យឯកជនមួយនៅរាជធានីភ្នំពេញ ។

## ១. ករណីជាសះស្បើយ៖ បុរសជនជាតិខ្មែរចំនួន ០២នាក់

- បុរសអាយុ ៣០ឆ្នាំ មានអាសយដ្ឋាននៅភូមិព្រៃខ្លា ឃុំបារាយណ៍ ស្រុកព្រៃឈរ ខេត្តកំពង់ចាម និង
- បុរសអាយុ ២៩ឆ្នាំ មានអាសយដ្ឋាននៅភូមិ ១ ឃុំឡាមិញ ស្រុកបរកែវ ខេត្តរតនគិរី

**សំគាល់៖** បុរសទាំង ០២នាក់ខាងលើ ជាអ្នកបានធ្វើដំណើរមកពីប្រទេសប៉ាគីស្ថាន បន្តជើងយន្តហោះនៅប្រទេសម៉ាឡេស៊ី មកប្រទេសកម្ពុជា ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

## ២. ករណីកូវីដ-១៩ថ្មី៖ ចំនួន ០២នាក់

### ២.១. ករណីស្ត្រីជនជាតិខ្មែរ ដែលជាក្រុមអ្នកទៀវអង្គការសហប្រជាជាតិរបស់កម្ពុជា ០១នាក់

- ស្ត្រីអាយុ ២៧ឆ្នាំ មានអាស័យដ្ឋាននៅព្រែកគ្រែង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល ជាក្រុមអ្នកទៀវអង្គការសហប្រជាជាតិរបស់កម្ពុជា បានវិលត្រឡប់មកពីប្រទេសម៉ាលី មកកាន់កម្ពុជា ដែលលទ្ធផលវិភាគវត្ថុសំណាកលើកទីប្រាំរបស់គាត់ ទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្ន អ្នកជំងឺ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យជ័យជំនះ ក្រុងតាខ្មៅ ខេត្តកណ្តាល។

### ២.២. ករណីស្ត្រីជនជាតិកាណាដា ០១នាក់

- ស្ត្រីជនជាតិកាណាដាអាយុ ៥១ឆ្នាំ រួមដំណើរមានកូនប្រុស ០១នាក់ និងកូនស្រី ០១នាក់ បានធ្វើដំណើរមកពីប្រទេស Ubekiztan ឆ្លងកាត់តាម ឌូបៃ និងបន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ទទួលបានលទ្ធផលវិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្ន អ្នកជំងឺ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។ ជើងហោះហើរនេះ មានអ្នកដំណើរសរុបចំនួន ៥៨នាក់ ក្នុងនោះមាន៖

- ជនជាតិខ្មែរ ១៩នាក់ (ស្ត្រី ០៩នាក់ កុមារ ០១នាក់)
- ជនជាតិអាមេរិចកាំង ២២នាក់ (ស្ត្រី ១០នាក់ កុមារ ០២នាក់)
- ជនជាតិកូរ៉េ ២៥នាក់ (ស្ត្រី ០៨នាក់ កុមារ ០១នាក់)
- ស្ត្រីជនជាតិចាម៉ៃកា (Jamaica) ០១នាក់
- ជនជាតិអង់គ្លេស ០៧នាក់ (ស្ត្រី ០៣នាក់ កុមារ ០១នាក់)
- បុរសជនជាតិអាល្លឺម៉ង់ ០៤នាក់
- ជនជាតិកាណាដា ០៤នាក់ (ស្ត្រី ០២នាក់ កុមារ ០២នាក់)
- ជនជាតិបារាំង ០២នាក់ (ស្ត្រី ០១នាក់)
- ស្ត្រីជនជាតិស្វីស ០១នាក់
- ស្ត្រីជនជាតិហ្វាំងឡង់ ០១នាក់
- បុរសជនជាតិអ៊ីស្រាអែល ០១នាក់
- បុរសជនជាតិហ្វីលីពីន ០២នាក់
- បុរសជនជាតិជប៉ុន ០១នាក់
- ជនជាតិចិន ០៣នាក់ (ស្ត្រី ០១នាក់) និង
- បុរសជនជាតិបែលហ្ស៊ិក ០១នាក់

**សម្គាល់៖** អ្នកដំណើរដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ ចំនួន ៧៨នាក់ នៅសណ្ឋាគារមួយទៀតក្នុងរាជធានីភ្នំពេញ ចំនួន ០៤នាក់ នៅមណ្ឌលចត្តាលីស័កអនុវិទ្យាល័យ ពោធិ៍ចិនតុង រាជធានីភ្នំពេញ ចំនួន ០៦នាក់ និងមន្ត្រីការទូតសហរដ្ឋអាមេរិកចំនួន ០៣នាក់ នៅក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា។ រីឯកូនទាំងពីរនាក់របស់ស្ត្រីជនជាតិកាណាដាខាងលើ ដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យស្នាក់ធ្វើចត្តាឡីស័ក នៅក្នុងលំនៅដ្ឋានមួយក្នុងរាជធានីភ្នំពេញ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ៥រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា